សង្កេតទិដ្ឋភាពព្រះរាជពិធីអុំទូកនៅមុខព្រះបរមរាជវាំង

ព្រះរាជពិធីបុណ្យអុំទូក តែងប្រារព្ធឡើងនៅត្រង់ទីប្រសព្វគ្នានៃទន្លេបួនមុខ[1] មុខព្រះដំណាក់ផែព្រះបរមរាជវាំង នៅក្នុងរាជធានីភ្នំពេញ។ ព្រះរាជទំនៀមដ៏មានសារៈសំខាន់នេះ ប្រារព្ធជាប្រក្រតីរយៈពេល៣ថ្ងៃ ពោលគឺពីថ្ងៃ១៤-១៥កើត និង១រោច ខែកត្តិក ដោយភ្ជាប់នឹងព្រះរាជពិធីបណ្តែតប្រទីបរៀងរាល់រាត្រី និងព្រះរាជពិធីសំពះព្រះខែ អកអំបុក ផ្សងទៀន នៅវេលារាត្រីថ្ងៃ១៥កើត។ ចំពោះវត្តមានទូកដែលបានឱកាសមកចូលរួមប្រណាំងក្នុងព្រះរាជពិធី ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ គឺជាទូកប្រចាំវត្តនានានៅតាមបណ្តាខេត្ត ជាពិសេសខេត្តមួយចំនួនធំដែលស្ថិតនៅតាមដងទន្លេ (រូបលេខ១)។ ប៉ុន្តែព្រះរាជទំនៀមនេះ ក៏ធ្លាប់អាក់ខានមិនបានប្រារព្ធដោយហេតុជាប្រការផ្សេងៗម្តងម្កាលផងដែរ។



រូបលេខ១ ព្រះមហាក្សត្រគង់ជាព្រះរាជាធិបតីក្នុងព្រះរាជពិធីអុំទូក នាទន្លេបួនមុខ មុខព្រះបរមរាជវាំង

(រូបថត៖ https://www.information.gov.kh)

[1] ទន្លេបួនមុខ ឬហៅម្យ៉ាងទៀតថា "ទន្លេចតុម្មុខ" គឺជាទីចំណុចប្រសព្វគ្នានៃទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាការពិតនៅក្នុងព្រះរាជពិធីបុណ្យអុំទូក ទូកដែលយកមកប្រណាំង គេហៅថា "ទូកង" ដែលមានពីរប្រភេទ គឺទូកអុំ និងទូកចែវ ហើយជាសម្បត្តិរួមរបស់វត្តណាមួយនៅក្នុងភូមិស្រុក។ ប៉ុន្តែជួនកាលវត្តខ្លះ មានតែទូកអុំ ឬទូកចែវ ហើយវត្តខ្លះទៀតមានទូកទាំងពីរ។ លុះពេលប្រណាំង អ្នកភូមិចំណុះជើងវត្តនោះឯងជាចំណុះទូកចូលរួមប្រណាំង ហើយមុនថ្ងៃបុណ្យអុំទូកមកដល់ ព្រះសង្ឃ ឬចាស់ទុំតែងប្រមូលគ្នា ដើម្បីហ្វឹកហាត់ ដ្បិតអ្នកប្រណាំងពុំមែនជាកីឡាករអាជីពឡើយ គេប្រកបរបរកសិជាធម្មតា ហើយមកហ្វឹកហាត់តែនៅពេលរៀបនឹងប្រណាំងប៉ុណ្ណោះ។

ជាទូទៅ គេសង្កេតឃើញថានៅក្នុងទំនៀមរបស់អ្នកស្រុក មុននឹងយកទូកទៅចូលរួមប្រណាំងនៅក្នុងពិធីបុណ្យអុំទូកនៅភ្នំពេញ គេត្រូវធ្វើពិធីប្រណាំងជម្រុះក្នុងភូមិស្រុកខ្លួនឯងសិន។ វត្ត ឬភូមិស្រុកខ្លះ តែងធ្វើពិធីប្រណាំងទូកជ្រើសរើសក្នុងវេលាភ្ជុំបិណ្ឌ និងខ្លះទៀតប្រណាំងនៅថ្ងៃចេញព្រះវស្សា ដើម្បីឲ្យមនុស្សម្នាបានមើលកម្សាន្តផង និងអបអរពិធីបុណ្យនោះឲ្យអធិកអធមផង។ លុះដល់ថ្ងៃព្រះរាជពិធីបុណ្យអុំទូកមកដល់ គេយកតែទូកដែលឈ្នះប៉ុណ្ណោះ ដើម្បីចាត់ជាតំណាងភូមិស្រុកនីមួយៗទៅប្រណាំងនៅឯរាជធានី។ ទំនៀមនេះគេឃើញមានបន្តប្រារព្ធមកវាប់សតវត្សមកហើយ (រូបលេខ២-៤)។ តាមប្រភពឯកសារខ្លះបញ្ជាក់ថាមានប្រវត្តិមកតាំងពីសម័យអង្គរ ពោលគឺដោយលើកសម្ពាធ ភ្ជាប់នឹងចម្ងាក់នៅលើជញ្ជាំងប្រាសាទ។[2]



រូបលេខ២ គំនូរការប្រណាំងទូកនៅកម្ពុជា (គូរដោយ៖ Édouard Garnier, ១៨៦០–១៩០៣)



រូបលេខ៣ ទិដ្ឋភាពក្នុងព្រះរាជពិធីអុំទូកមុខព្រះដំណាក់ផៃ នាដើមសតវត្សទី២០ (ប្រភព៖?)

[2] ចាប ពិន, ១៩៦៩, ទំ.១១៩-១៣៦



រូបលេខ៤ ទិដ្ឋភាពក្នុងព្រះរាជពិធីបុណ្យអុំទូកមុខព្រះបរមរាជវាំង ត្រៀមរៀបចំកាត់ព្រ័ត្រ ក្នុងឆ្នាំ២០១៩

ក្នុងព្រះរាជពិធីអុំទូកពីមួយឆ្នាំទៅមួយឆ្នាំ តែងមានទូកចូលរួមប្រមាណពី៤០០ទៅ ៦០០ ហើយទូកនីមួយៗត្រូវចាប់ឆ្នោតដើម្បីរើសគូប្រកួត ដែលរៀបចំដោយគណៈកម្មការ រៀបចំការប្រណាំង។ ទន្ទឹមនឹងនោះ ទូកដែលជាតំណាងមកពីភូមិស្រុកនីមួយៗតែងមាន គណៈកម្មការដឹកនាំពីស្រុកភូមិមកចូលរួម។ ទូកប្រចាំវត្តខ្លះត្រូវធ្វើដំណើរមកចូលរួមមុន ថ្ងៃកំណត់ពីរ ឬបីថ្ងៃ ដោយរាប់តាំងពីការដឹកជញ្ជូន ការស្នាក់នៅ និងការហូបចុកប្រកប ដោយសាមគ្គីភាព (រូបលេខ៥-៦)។ មិនតែប៉ុណ្ណោះបើតាមការសង្កេត នៅក្នុងអំឡុងពេល ស្នាក់នៅត្រៀមប្រកួត ចំណុះទូកទាំងអស់តែងតែរៀបចំថ្វាយគ្រឿងសក្ការៈបូជាទូករបស់ ខ្លួនទៅតាមទំនៀមពុំដែលដាច់ (រូបលេខ៧-១០)។ មកដល់ចំណុចនេះ សូមបញ្ជាក់ថាទូក ប្រពៃណីទាំងពីរប្រភេទ ពោលគឺទូកអុំភាគច្រើនមានប្រវែងជាមធ្យមចាប់ពី៣២ទៅ៣៦ ម៉ែត្រ សម្រាប់ចំណុះទូកពី៦៥ទៅ៧៥នាក់។ ទូកចែវ (ឬទូកមួង) មានប្រវែងជាធម្យមចាប់ ពី២៧ទៅ៣១ម៉ែត្រ សម្រាប់ចំណុះទូកពី២៨ទៅ៤៨នាក់ ឬបច្ចុប្បន្នមានរហូតដល់៥០ ទៅ៦០នាក់។ អ្នកស្រុកយល់ថារាល់ទូកនីមួយៗតែងមានបារមី(អ្នកស្រុកខ្លះហៅថា "រក្សា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ទូក") ឬអមនុស្សថែរក្សា ជាពិសេសគឺមាន"ព្រាយ"កាន់នៅចាំមើលថែរក្សាជានិច្ច។[3] គេតែងថ្វាយក្ងស់នៅផ្នែកខាងក្បាលទូក ទាំងពេលរក្សាទុកនៅក្នុងរោង និងពេលចុះទឹកសំចតមុន និងក្រោយអុំ។




រូបលេខ៥-៦ សកម្មភាពដឹកជញ្ជូន និងរៀបចំកិច្ចដាក់ទូកសំចតក្នុងទន្លេត្រៀមចាំប្រណាំងផ្លូវការ




រូបលេខ៧-៨ ព្រះសង្ឃព្រះថៅអធិការវត្តនិមន្តប្រស់ព្រំចំណុះទូកដែលមកដល់រាជធានីភ្នំពេញ




រូបលេខ៩-១០ សកម្មភាពធ្វើកិច្ចបួងទូក និងព្រមទាំងការហាត់សមមុនប្រកួត

[3] Ang Chouléan 1986: 138-141

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមបច្ចេកទេសរៀបចំការប្រកួត ចំពោះក្នុងទូកមួយគូ ត្រូវប្រណាំងពីរដង ពោលគឺម្តងអុំនៅខ្សែទឹកខាងក្រៅ ហើយម្តង ទៀតបត្តូរមកខ្សែទឹកខាងក្នុងវិញ។ ទីប្រណាំងគឺចាប់ផ្តើមចេញពីក្បែរស្ពានជ្រោយចង្វា ហើយអុំបណ្តោយខ្សែទឹកមកមុខព្រះបរមរាជវាំងត្រង់ដំណាក់ផែ(ឬវេទិកា) ដែលជាទីផ្តាច់ព្រ័ត្រ និងជាទីដែលព្រះមហាក្សត្រ និងគណអធិបតី គង់ទត និងទស្សនា។ ទូកដែលប្រណាំងឈ្នះនៅថ្ងៃទី១ និងថ្ងៃទី២ ត្រូវទៅប្រណាំងបន្តនៅថ្ងៃទី៣ ដែលជាថ្ងៃផ្តាច់ព្រ័ត្រ។ នៅពេលបញ្ចប់ការប្រណាំង មានកិច្ចសំខាន់មួយហៅថា "កាត់ព្រ័ត្រ" ដែលធ្វើដោយក្រុមព្រាហ្មណ៍បាគូប្រចាំព្រះបរមរាជវាំង។[4]

ដោយឡែក បើបកត្រឡប់ទៅមើលសារបានខ្លះនៃព្រះរាជពិធីបុណ្យអុំទូកនេះវិញ គេឃើញមានការវិវត្តប្រែប្រួលគួរកត់សម្គាល់។ ក្នុងព្រះរាជកំណត់បុណ្យទ្វាទសមាសឆ្នាំ ១៩០៧ និងឆ្នាំ១៩៣៧ ជារៀងរាល់ថ្ងៃគឺចាប់ពីម៉ោង៣រសៀល គេតែងចាប់ផ្តើមការប្រណាំងទូក។ លុះម៉ោង៥ ព្រះករុណាជាអម្ចាស់លើត្បូង ស្តេចយាងប្រថាប់ព្រះទីនាំងម្ភរធំ រហូតម៉ោង៦ទ្រង់យាងអុជទៀនប្រទីប និងកន្ទោងធំ។ ម៉ោង៨ ស្តេចយាងប្រថាប់ក្នុងព្រះដំណាក់ផែ ទ្រង់ព្រះសណ្តាប់ចម្រៀងសកវារ៍ និងទតរបាំព្រះរាជទ្រព្យ។ នៅរាត្រីថ្ងៃ១៥កើត ស្តេចទ្រង់យាងប្រារព្ធព្រះរាជពិធីសំពះព្រះខែ និងអកអំបុកក្នុងព្រះដំណាក់ផែ[5] (រូបលេខ១១-១២)។ ប៉ុន្តែបច្ចុប្បន្ន ព្រះរាជពិធីសំពះព្រះខែ អកអំបុកប្រារព្ធនៅប្រាសាទទេវាវិនិច្ឆ័យ ខាងក្នុងបរិវេណព្រះបរមរាជវាំង។



រូបលេខ១១ ព្រះដំណាក់ផែក្នុងសម័យបារាំង (ប្រភព៖ delcampe.net)



រូបលេខ១២ ព្រះរាជដំណាក់ផែសម័យសង្គមរាស្ត្រនិយម (ប្រភព៖ អនុស្សាវរីយ៍ដោយរូបភាព)

[4] ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ២០២៦, ទំ.១៩០-១៩២

[5] សូមអាន៖ ព្រះរាជកំណត់បុណ្យទ្វាទសមាស ឆ្នាំ១៩០៧ និងឆ្នាំ១៩៣៧។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សូមរម្លឹកថា ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ដែលជាព្រះរាជពិធីថ្នាក់ជាតិនេះ ក៏ធ្លាប់អាក់ខានមិនបានប្រារព្ធដោយហេតុផ្សេងៗដូចបញ្ជាក់មកខាងលើដែរ។ ក្នុងសម័យសង្គ្រាមរវាងឆ្នាំ១៩៧០ ដល់១៩៧៨ ព្រះរាជទំនៀមនេះបានផ្អាកជាស្ថាពរ រហូតដល់ឆ្នាំ១៩៩០ ទើបរដ្ឋាភិបាលបានចាប់ផ្តើមកសាងប្រទេសជាតិឡើងវិញ ដោយរៀបចំឱ្យមានការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក និងទំនៀមពាក់ព័ន្ធឡើងវិញ។ គ្រានោះចំនួនទូកចូលរួមប្រកួតមានចំនួនត្រឹមតែ៤៣ទូកប៉ុណ្ណោះ ដែលជាទូកក្នុងក្រុងភ្នំពេញ និងមកពីបណ្តាខេត្តជាប់ដងទន្លេ[6] ព្រះរាជទំនៀមនេះចេះតែបន្តប្រារព្ធ និងរីកចម្រើន មានចំនួនទូកចូលរួមកើនឡើងរហូតរាប់រយគូ។ ប៉ុន្តែមកដល់ឆ្នាំ២០១១ ព្រះរាជទំនៀមថ្នាក់ជាតិនេះក៏ត្រូវផ្អាកវិញដោយសារប្រទេសជាតិជួបគ្រោះទឹកជំនន់។ ឆ្នាំ២០១២ ត្រូវផ្អាកម្តងទៀត ដោយកម្ពុជាត្រូវកំណត់កាន់ទុក្ខនៃការយាងសោយទិវង្គត **ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ**។ ឆ្នាំ២០១៣ និងឆ្នាំ២០១៥ ត្រូវផ្អាកដោយសារកម្ពុជាជួបគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាបន្តបន្ទាប់។ ឆ្នាំ២០២០ និងឆ្នាំ២០២១ ត្រូវផ្អាកដោយសារវិបត្តិសកលជំងឺកូវីដ-១៩ ហើយនៅឆ្នាំ២០២២ ត្រូវផ្អាកដោយសារកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន និងឆ្នាំ២០២៥ និងឆ្នាំ២០២៦ រាជរដ្ឋាភិបាលកំណត់ឱ្យផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ដោយរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ដោះស្រាយបញ្ហានៅតាមព្រំដែនកម្ពុជា-ថៃ និងបញ្ហាប្រជាពលរដ្ឋភៀសសឹក។[7]

[6] ជា គាន, ១៩៩១, ទំ.២៣-២៤

[7] សារាចរ លេខ១៥ ស.រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ និងសារាចរ លេខ១០ ស.រ. ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ឯកសារយោង

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០២៦, *បញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីកម្ពុជា*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

ចាប ពិន

១៩៦៩, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ជា គាន

១៩៩១,ប្រវត្តិដង្វេកើ អុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក, ភ្នំពេញ

Ang Chouléan

1986, *Les êtres surnaturels dans la religion populaire khmère,* Cedoreck, Paris

សូមអានបន្ថែម៖ ព្រះរាជកំណត់បុណ្យទ្វាទសមាស ឆ្នាំ១៩០៧ និងឆ្នាំ១៩៣៧

សូមអានបន្ថែម៖ សារាចរ លេខ១៥ ស.រ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ ស្តីពីការផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ។

សូមអានបន្ថែម៖ សារាចរ លេខ១០ ស.រ. ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ ស្តីពីការផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ។